00342731

D158/5/4/12

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ ១៩)

ដាក់ជូន: អង្គបុរេជំនុំជម្រះ

កាលបរិច្ឆេទដាក់ឯកសារ: ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩

ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីរបស់អ្នកស្រី **អៀង ធីរិទ្ធ**

ភាសា: ភាសាអង់គ្លេស និង ភាសាខ្មែរ (អត្ថបទបកប្រែ)

ប្រភេទឯកសារស្នើឡើង
ដោយភាគីដាក់ឯកសារ: សាធារណៈ

---

**ចម្លើយតបទៅនឹង ក.ស.ព ចំពោះបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ស្តីពីការចោទប្រកាន់អំពើពុករលួយ**

---

__ដាក់ឯកសារដោយ៖__

**សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLI, QC

__ចែកចាយជូន៖__

**សហចៅក្រមស៊ើបអង្កេត**

លោក យូ ប៊ុនឡេង

លោក Marcel LEMONDE

**សហព្រះរាជអាជ្ញា:**

អ្នកស្រី ជា លាង

លោក Robert PETIT

ក្រុមមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់

ដើមបណ្តឹងរដ្ឋប្បវេណីគ្មានតំណាង

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 23 / 06 / 2009
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Ly

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 23 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Ly

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៩, អង្គបុរេជំនុំជម្រះ (អបជ) បានចេញសេចក្តីបង្គាប់ដល់សហមេធាវីការពារក្តីរបស់ជនត្រូវចោទដែលពាក់ព័ន្ធទៅនឹងភាពទទួលយកបាននៃបណ្តឹង ("សេចក្តីបង្គាប់")[1] បានបង្គាប់ឲ្យសហមេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងភាពទទួលយកបាននៃបណ្តឹងរបស់ អ្នកស្រី អៀង ធីរិទ្ធ[2] ឯកសារនេះត្រូវបានដាក់ដោយអនុលោមទៅនឹងសេចក្តីបង្គាប់នេះ។

## II. ប្រវត្តិ

2. នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៩,មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ បានដាក់សំណើសុំឲ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរ[3]។ សំណើសុំត្រូវបានបដិសេធតាមរយៈសេចក្តីសម្រេចចុះថ្ងៃទី ៣ ខែ មេសា ២០០៩[4]។

3. នៅថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០០៩, មេធាវីការពារក្តីជនត្រូវចោទ អ្នកស្រី អៀង ធីរិទ្ធបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ(បណ្តឹងឧទ្ធរណ៍អ្នកស្រី អៀង ធីរិទ្ធ)[5] ដោយសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស)ដែលបានបដិសេធសំណើសុំរបស់មេធាវីការពារក្តី និង សំណើសុំរបស់មេធាវីការពារជនត្រូវចោទបីផ្សេងទៀត[6]។

---

[1] សេចក្តីបង្គាប់ដល់សហមេធាវីការពារក្តីជនត្រូវចោទពាក់ព័ន្ធនឹង " ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចបដិសេធរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើសុំឲ្យមានកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពើពុករលួយ" របស់ អបជ។

[2] កថាខណ្ឌទី ៣ នៃសេចក្តីបង្គាប់ ។

[3] ញត្តិគាំទ្រលើសំណើសុំលើកទី១១របស់លោក នួន ជាស្នើសុំបំពេញកិច្ចស៊ើបសួរដើម្បីបង្ហាញរបាយការណ៍ OIOS និងឯកសារដែល ជាប់ពាក់ព័ន្ធ, ចុះថ្ងៃទី ៣០ ខែ មីនា ២០០៩, ឯកសារលេខ:D158/3 ។

[4] សេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទិ ៣ ខែ មេសា ២០០៩, ឯកសារលេខ:D158/5 ។

[5] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី ៤ ខែ ឧសភា ២០០៩, ប្រឆាំងនឹងដីកាសម្រេចរបស់កសចស លើសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣ ខែ មេសា ២០០៩, ឯកសារលេខ:D158/5/4/1 ។

[6] បណ្តឹងឧទ្ធរណ៍លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទី១១ សុំបំពេញកិច្ចស៊ើបសួរចុះថ្ងៃទី ៤ ខែ ឧសភា ២០០៩, ឯកសារលេខ:D158/5/1/1។ បណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ នាខែមេសា ២០០៩, ចុះថ្ងៃទី ៤ ខែ ឧសភា ២០០៩, ឯកសារលេខ:D158/5/2/1។ បណ្តឹងឧទ្ធរណ៍របស់លោកចម្លើយតបរបស់អ្នកស្រី អៀង ធីរិទ្ធ ចំពោះភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ" ។

4. នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៩, ការិយាល័យសហព្រះរាជអាជ្ញា បានដាក់ចម្លើយតបរួម ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីទាំងបួនក្រុម (ចម្លើយតបរបស់ ក.ស.ព)[7] ។

## III. សេចក្ដីសន្និដ្ឋានលើភាពទទួលយកបាននៃបណ្ដឹង

5. សេចក្ដីបង្គាប់របស់ អ.ប.ជ ដែលបានស្នើសុំឲ្យសហមេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធ ឆ្លើយតបទៅនឹងចម្លើយរបស់ ក.ស.ព“ កំណត់ត្រឹមតែបញ្ហានៃការទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍”។

6. មេធាវីការពារក្ដីយល់ឃើញថា បញ្ហាដែល អបជ បានចង្អុលបង្ហាញឲ្យដោះស្រាយថាតើមេធាវីការពារក្ដី អ្នកស្រី អៀងធីរិទ្ធ មានសិទ្ធិថ្លែងអំណះអំណាងនៅចំពោះមុខ អបជ ដែរឬទេអំពីបណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចខាងលើរបស់សហចៅក្រមស៊ើបអង្កេត ឬថាតើមេធាវីការពារក្ដីគ្រាន់តែកំណត់យកតាមអំណះអំណាងដែលដាក់ជាលាយលក្ខអក្សរដោយមេធាវីការពារក្ដី លោក នួន ជា ប៉ុណ្ណោះ។ មេធាវីការពារក្ដី សូមរក្សាសិទ្ធិរបស់ខ្លួនដើម្បីមានវត្តមាននៅសវនាការ និងទាញហេតុផលដោយឡែកនៅក្នុងការគាំទ្របណ្ដឹងឧទ្ធរណ៍របស់ខ្លួន។

7. មេធាវីការពារក្ដីបានដាក់ឯកសារបណ្ដឹងឧទ្ធរណ៍ដាច់ដោយឡែក និងមិនបានដាក់រួមគ្នាជាមួយនឹងបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទផ្សេងទៀតប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនោះទេ។ ហេតុដូច្នេះ មេធាវីការពារក្ដីសូមរក្សាសិទ្ធិរបស់ខ្លួនដើម្បីប្ដឹងឧទ្ធរណ៍ទៅនឹងសេចក្ដីសម្រេចនោះ។ នៅក្នុងចំណុចនេះ វាមិនមានបញ្ហារវាង ក.ស.ព និងមេធាវីការពារក្ដីអំពីភាពទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍។ នៅក្នុងផ្នែកទី ៣.២ នៃចម្លើយតបរបស់ ក.ស.ព ដែលដាក់ចំណងជើងថា“ ភាពទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍ពុំត្រូវបានបដិសេធទេ” ដែលបានកំណត់ជំហរយ៉ាងច្បាស់គឺថា ក.ស.ព មិនបានបដិសេធនូវភាពទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍នេះទេ។

---

អៀង សារី ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ និងសំណើសុំឲ្យមានសវនាការផ្ទាល់មាត់ឲ្យបានឆាប់រហ័ស ចុះថ្ងៃទី ៤ ខែ ឧសភា ២០០៩, ឯកសារលេខ:D158/5/3 ។ ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរចុះថ្ងៃទី ៣ ខែ មេសា ២០០៩, ឯកសារលេខ:D158/5 ។

[7] ចម្លើយតបរួមរបស់ ក.ស.ពទៅនឹងបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីប្រឆាំងនឹងដីកាបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរលើការចោទប្រកាន់អំពើពុករលួយ ចុះថ្ងៃទី ២៩ ខែ ឧសភា ២០០៩, ឯកសារលេខ:D158/5/4/10 ។

00342734



8. តុលាការត្រូវកំណត់ជាចុងក្រោយកាលណាមានបញ្ហានៃភាពទទួលយកបាននៃបណ្តឹង។ នៅពេលដែលមេធាវីការពារក្តី និង ក.ស.ព បានព្រមព្រៀងគ្នាលើបញ្ហានេះហើយ ហេតុដូច្នេះ យើងស្នើសុំថានេះជាហេតុផលបង្ខំមួយដែលចាត់ទុកបណ្តឹងឧទ្ធរណ៍នេះថាទទួលយកបាន។

## IV. សេចក្តីសន្និដ្ឋានលើសវនាការផ្ទាល់មាត់

9. ដោយអនុលោមតាមវិធាន ៧៧ នៃវិធានផ្ទៃក្នុង, មេធាវីការពារក្តីសូមលើកឡើងថាខ្លួនមានសិទ្ធិដើម្បីមានវត្តមាននៅសវនាការផ្ទាល់មាត់នៃបណ្តឹងឧទ្ធរណ៍ ដោយហេតុផលថាខ្លួនគឺជាភាគីនៃដំណើរការនីតិវិធីនៃបណ្តឹងឧទ្ធរណ៍។ ក.ស.ព មិនបានជំទាស់អំពីបញ្ហាសិទ្ធិរបស់អ្នកស្រី អៀង ធីរិទ្ធ ដើម្បីមានវត្តមាននៅសវនាការបណ្តឹងឧទ្ធរណ៍នេះទេ[8]។

10. ក.ស.ពបានកំណត់លក្ខណៈមិនត្រឹមត្រូវចំពោះវត្តមានរបស់សហមេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ថា " មិនសូវចាំបាច់ដោយហេតុថាបណ្តឹងឧទ្ធរណ៍របស់គាត់គ្រាន់តែយកអំណះអំណាងដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ លោក នួន ជា ទាំងស្រុង"[9] ។

11. សវនាការផ្ទាល់មាត់មួយជាពិសេស សវនាការដែលជំនួសឱ្យការឆ្លើយតបមួយដ៏មានសារៈសំខាន់គឺជាពេលវេលាមួយសំរាប់មេធាវីការពារក្តីដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងនៅក្នុងចម្លើយរបស់ ក.ស.ព ហើយ មេធាវីការពារក្តីនៅមិនទាន់បានដោះស្រាយជាមួយនឹងឯកសារដើមរបស់ខ្លួននៅឡើយ។ វាមិនមានយុត្តិធម៌ទេ ហើយនិងនាំឱ្យមានព្យសនកម្មដល់ជនត្រូវចោទក្នុងការបដិសេធមិនបញ្ចូលមេធាវីការពារក្តីរបស់គាត់ ក្នុងការឆ្លើយតបទៅនឹងអំណះអំណាងដែលបានលើកឡើងនៅក្នុងចម្លើយតបរបស់ ក.ស.ព ជាពិសេសទាក់ទងនឹងកង្វល់ដែល ក.ស.ព បានលើកឡើងនៅក្នុងចម្លើយតបរបស់ខ្លួន ហើយដែលមិនទាន់បានដោះស្រាយជាមួយនឹងបណ្តឹងឧទ្ធរណ៍របស់ អ្នកស្រី អៀង ធីរិទ្ធ។

12. សវនាការផ្ទាល់មាត់មិនគ្រាន់តែផ្តល់ឱកាសសំរាប់សហមេធាវីការពារក្តីក្នុងការអានសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរប៉ុណ្ណោះទេ តែវាក៏ជាការធ្វើយុត្តិកម្មមួយសំរាប់សវនាការផ្ទាល់មាត់

---

[8] កថាខណ្ឌទី ១៦ នៃចម្លើយតបរបស់ ក.ស.ព ។

[9] កថាខណ្ឌទី ១៧ នៃចម្លើយតបរបស់ ក.ស.ព ។

នោះដែរ។ សារៈសំខាន់នៃសវនាការផ្ទាល់មាត់គឺថាវាអនុញ្ញាតឲ្យមានការទាញហេតុផល និង អធិប្បាយនៅចំពោះមុខចៅក្រមទាំងអស់របស់ អ.ប.ជ ។ ចំណុចនេះរួមទាំងឱកាសដើម្បីឆ្លើយតបទៅនឹងចំណុចដែលបានលើកឡើងដោយភាគីផ្សេងទៀតនៃដំណើរការនីតិវិធីគឺតាមរយៈសហមេធាវីការពារក្ដីរបស់ជនត្រូវចោទផ្សេងទៀត, សហព្រះរាជអាជ្ញា និង ចៅក្រមរបស់ អ.ប.ជ។ ចំណុចថ្មីដែលមិនអាចចៀសរួចនឹងកើតឡើងចេញពីលទ្ធផលនៃការទាញហេតុផលដែលលើកឡើង ហើយនិងត្រូវបកស្រាយនូវចរិតលក្ខណៈនៃបញ្ហាទាំងនោះ។

13. មេធាវីការពារក្ដីបានបញ្ជាក់យ៉ាងច្បាស់តាមរយៈការយកតាមចំណុចសំខាន់ៗដែលបានធ្វើឡើងក្នុងនាម លោក នួន ជា នៅក្នុងឯកសារបណ្ដឹងឧទ្ធរណ៍របស់គាត់ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ មេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធ មិនបានសុខចិត្តឲ្យសហមេធាវីលោក នួន ជា អាច ឬ មាន លទ្ធភាពគ្រាប់គ្រាន់ដើម្បីទាញហេតុផលលើបណ្ដឹងឧទ្ធរណ៍ក្នុងនាមអ្នកស្រី អៀង ធីរិទ្ធ នោះទេ ។

14. មេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធរំពឹងថានឹងលើកឡើងនូវបញ្ហាខុសៗគ្នា ហើយនិងដោះស្រាយបញ្ហានោះផ្សេងៗគ្នាខុសពីការបង្ហាញដោយសហមេធាវីការពារក្ដី លោក នួន ជា ដោយសារថា លក្ខណៈខុសគ្នានៃរឿងក្ដីប្រឆាំងនឹងជនត្រូវចោទនីមួយៗនៅពេលសវនាការផ្ទាល់មាត់។ ការដែលថាការទាញហេតុផលនៅក្នុងបណ្ដឹងឧទ្ធរណ៍ដំបូងអាចប្រៀបធៀបបាន គឺមិនមានន័យថាអំណះអំណាងដែលត្រូវបានលើកឡើងនៅសវនាការមួយនោះនឹងត្រូវដូចគ្នាសុទ្ធសាធនោះទេ។

15. មេធាវីការពារក្ដីសូមលើកឡើងថា វាមិនយុត្តិធម៌ទេ ហើយវាក៏ជាការបដិសេធយុត្តិធម៌របស់អ្នកស្រី អៀង ធីរិទ្ធដែលគាត់មិនត្រូវបានផ្ដល់ឱកាសឲ្យចូលរួមនៅក្នុងដំណាក់កាលនៃដំណើរការបណ្ដឹងឧទ្ធរណ៍នេះ។ មេធាវីការពារក្ដីសូមលើកឡើងថាវានាំឲ្យមានព្យសនកម្មដល់អ្នកស្រី អៀង ធីរិទ្ធ ក្នុងករណីដែលសហមេធាវីការពារក្ដីរបស់គាត់មិនត្រូវបានផ្ដល់ឱកាសដើម្បីទាញហេតុផលដោយផ្ទាល់នោះ។ ដោយគ្រាន់តែការយកតាមសេចក្ដីសន្និដ្ឋានជាលាយលក្ខអក្សរ វាមិនមានន័យថាត្រូវធ្វើតាមដោយសមហេតុផល ហើយថា: សហមេធាវីមិនមានចំណុចសំខាន់ៗដើម្បីពិភាក្សាដេញដោលក្នុងនាមជនត្រូវចោទនៅពេលសវនាការលើបណ្ដឹងឧទ្ធរណ៍។

## V. សំណូមពរ

16. សំរាប់ហេតុផលដែលបានលើកឡើងខាងលើ មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធសូមស្នើថាៈ

(i) បណ្តឹងឧទ្ធរណ៍គឺអាចទទួលយកបាន

(ii) សុំឱ្យមានសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍

(iii) ជនត្រូវចោទ អ្នកស្រី អៀង ធីរិទ្ធ គប្បីមានវត្តមាននៅសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍នេះ។

17. សហមេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធគប្បីត្រូវតែបានអនុញ្ញាតឱ្យមានវត្តមាននៅពេលសវនាការនៃបណ្តឹងឧទ្ធរណ៍ ហើយអនុញ្ញាតឱ្យចូលរួមគ្រប់ដំណាក់កាលនៅក្នុងដំណើរការនីតិវិធីនៃបណ្តឹងឧទ្ធរណ៍។

18. ផលប្រយោជន៍របស់អ្នកស្រី អៀង ធីរិទ្ធ មិនរួមគ្នាជាមួយនិងផលប្រយោជន៍របស់ លោក នួន ជា ទេ ហើយអ្នកស្រីក៏មិនអាចត្រូវបានតំណាងយ៉ាងគ្រប់គ្រាន់, ត្រឹមត្រូវ និងយុត្តិធម៌ដោយសហមេធាវីការពារក្តីរបស់លោក នួន ជា បានទេ។

19. ការបដិសេធមិនឱ្យសហមេធាវីការពារក្តី នូវលទ្ធភាពដើម្បីចូលរួមដោយសកម្មនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ នឹងបង្កើតនូវភាពគ្មានយុត្តិធម៌នៅក្នុងគ្រប់កាលៈទេសៈទាំងអស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

សហមេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ

**លោក ផាត់ ពៅស៊ាង**

**កញ្ញា Diana ELLIS, QC**